**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

12 JUL 2007

លេខ: ៣៤/០៧ ម.ស.រ.ស២ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី**

**សម្តេចព្រះមហាសង្ឃរាជ នៃ ព្រះរាជាណាចក្រកម្ពុជា**

# <u>សេចក្តីបំភ្លឺ</u>

ការអនុញ្ញាតឱ្យផ្សឹកតាមសំណូមពរអ្នកច្បាប់ និងអនុវត្តតាមមាត្រាទី៣៧ និងមាត្រាទី៤៣ របស់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងការឱ្យវិលត្រឡប់តាមសំណូមពររបស់ទណ្ឌិត **ទឹម សាខន** ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ ដូចបានផ្ញើភ្ជាប់មកជាមួយសូមបញ្ជាក់ថា: ទណ្ឌិត **ទឹម សាខន** និងក្រុមបក្សពួកមិនដែលទទួលស្គាល់ព្រះពុទ្ធសាសនា ថាជាសាសនារបស់រដ្ឋម្តងណាឡើយ ទោះបីនៅទីណា ក៏ដូចជាកន្លែងណា ពួកក្រុមនេះបានចាត់ទុកព្រះពុទ្ធសាសនារបស់រដ្ឋជាសាសនាអាយ៉ង ។ ពួកគេបង្អាប់បន្ទុះទៅលើ**សម្តេចព្រះមហាសង្ឃរាជ** ដែលជាព្រះបិតាសង្ឃថាជាស្តេចសង្ឃកុម្មុយ-នីស្ត ស្តេចសង្ឃគ្មានធម៌វិន័យ ស្តេចសង្ឃអាយ៉ងរបស់ **ហ៊ុន សែន** ។ ចំពោះទណ្ឌិត **ទឹម សាខន** មិនត្រឹមតែមិនទទួលស្គាល់ព្រះពុទ្ធសាសនា ថាជាសាសនារបស់រដ្ឋប៉ុណ្ណោះទេ ថែមទាំងបានតាំងខ្លួនធ្វើសកម្មភាពបំផ្លាញព្រះពុទ្ធសាសនាមានទ្រង់-ទ្រាយយ៉ាងធំធេង គួរឱ្យភ័យខ្លាច និងញ័ររន្ធត់ ដូចជាបង្កើតក្រុមចលនាបំបែកបំបាក់សាមគ្គីរវាងកម្ពុជា-វៀតណាម ជាក់ស្តែងបានធ្វើបាតុកម្ម ០២ លើក ប្រឆាំងនឹងមិត្តភាព សាមគ្គីភាពរវាងកម្ពុជា-វៀតណាម និងរហូតឈានដល់ធ្វើការប្រឆាំងជាមួយនឹងសមណសិស្ស សមណនិស្សិត អ្នកបួសក្នុងសាសនា ដោយចាត់ទុកថាជាសង្ឃអាជ្ញាធររបស់ **ហ៊ុន សែន** ដែលមានចំនួនប្រមាណ២០អង្គ ទៅការពារសុវត្ថិភាព សន្តិសុខដល់ក្រុមបាតុកម្មខុសច្បាប់ តែពួកគេដែលមិនទទួលស្គាល់ព្រះពុទ្ធសាសនា ថាជាសាសនារបស់រដ្ឋនោះ គេបានប្រមូលកម្លាំងគ្នាចំនួន៦០អង្គ មកដល់មុខវត្តឧណ្ណាលោម ហើយបានបញ្ចេញនូវសកម្មភាពហិង្សាមកលើព្រះសង្ឃ ដែលជាអ្នកសម្របសម្រួលក្រុមពួកគេនោះ ដោយប្រើសម្ភារៈផ្សេងៗមាន ពូថៅ និងដំបង ជាដើម ដេញកាប់ព្រះសង្ឃ សមណសិស្ស សមណនិស្សិត ដែលមានគ្នាប្រមាណ២០អង្គ ហើយបង្កឱ្យមានក្រុមសម្របសម្រួលរងរបួស៤អង្គ ។ ដោយមើលឃើញនូវអំពើហិង្សាបែបនេះ ក្រុមសម្របសម្រួលក៏បង្ខំចិត្តចូលមកវត្តឧណ្ណាលោម ។ ទាំងអស់នេះ គឺជាទង្វើអសីលធម៌របស់ទណ្ឌិត **ទឹម សាខន** បានបំផ្លាញព្រះពុទ្ធសាសនា ០៧ មករា យ៉ាងមានទ្រង់ទ្រាយធំបំផុត ដែលទង្វើនេះឈានដល់**ទោសសង្ឃភេទ** បំបែកបំបាក់សង្ឃជាពួក ជាក្រុម ត្មះតិះដៀលដល់ព្រះពុទ្ធសាសនា ដែលគេចាត់ទុកព្រះសង្ឃគ្មានធម៌ គ្មានវិន័យ ទង្វើនេះជាការគួរឱ្យភ័យខ្លាចបំផុតចំពោះការបាត់បង់ព្រះពុទ្ធសាសនា ដែលជាឧត្តមប្រយោជន៍របស់ប្រជាពុទ្ធសាសនិក ។ ដូច្នេះហើយទើបអ្នកច្បាប់ និងព្រះវិន័យធរសង្ឃ បានបើកអង្គប្រជុំសង្ឃ និងអ្នកច្បាប់ វែកញែកទង្វើរបស់ទណ្ឌិត **ទឹម សាខន** ឈានចូលដល់កក្រិតណាហើយ ព្រះវិន័យធរសង្ឃ និងអ្នកច្បាប់សម្រាប់រដ្ឋ បានឯកភាពគ្នាថាជាទោសបំបែកបំបាក់សាមគ្គីសង្ឃ ចូលដល់**ទោសបារាជិក** និង **ផ្ទាក់ព្រហ្មទណ្ឌ** ត្រូវតែលាចាកសិក្ខាបទ ។

សេចក្តីដូចបានបំភ្លឺ និងពន្យល់ខាងលើនេះ ទើបមានសំណូមពរពីព្រះវិន័យធរសង្ឃ និងអ្នកច្បាប់ តាមរយៈ**សម្តេចព្រះមហាសុមេធាធិបតី** សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា, **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ** នៃព្រះរាជាណាចក្រកម្ពុជា ក៏ទ្រង់ព្រះអនុញ្ញាតឱ្យទណ្ឌិត **ទីម សាខន** លាចាកភេទពីបព្វជិតតាមប្រពៃណីនៃច្បាប់ព្រះពុទ្ធសាសនា និងច្បាប់សម្រាប់រដ្ឋជាធរមាន ។ ប៉ុន្តែ ទណ្ឌិត **ទីម សាខន** រូបនេះ គឺជាមនុស្សទិដ្ឋិរឹងរូស នៅតែប្រឆាំងនឹងព្រះពុទ្ធសាសនាជានិច្ច យ៉ាងនេះហើយអ្នកច្បាប់ត្រូវតែអនុវត្តតាមមាត្រានៃច្បាប់រដ្ឋធម្មនុញ្ញដូចខាងលើ ពុំមានអាជ្ញាធររដ្ឋបាល មន្ត្រីរាជការណាមួយបានចូលរួមជាក់ស្តែងនោះទេ គឺសុទ្ធតែមន្ត្រីសង្ឃដែលមានសិទ្ធិបំបួសបាន និងផ្សឹកបាន ទើបគេហៅមកផ្សឹក ថែមទាំងបានធ្វើការឆែកឆេរទៅឃើញមានអាវុធ (កាំបិតសាំងតឹម) នៅជាប់ក្នុងថង់យាមជាអចិន្ត្រៃយ៍ នេះជាភស្តុតាងមួយ, មួយទៀត រដ្ឋាភិបាលមានសមត្ថកិច្ច និងមន្ត្រីសង្ឃបានចាត់កម្លាំងឆែកឆេរនៅក្នុងកុដិ ជាក់ស្តែងនៅក្នុងបន្ទប់របស់ ទណ្ឌិត **ទីម សាខន** ផ្ទាល់ បានរកឃើញនូវឯកសារជាច្រើនដូចជា VCD អាសអាភាស ហើយថែមទាំងមានស្ត្រីមួយរូបដេកនៅលើគ្រែក្នុងបន្ទប់របស់ទណ្ឌិត **ទីម សាខន** ផ្ទាល់ ព្រមទាំងសម្ភារៈរបស់ស្ត្រីនោះមួយចំនួនថែមទៀតនៅលាយឡំជាមួយបរិក្ខារទណ្ឌិត **ទីម សាខន** ទើបក្រុមការងារត្រួតពិនិត្យបានយកភស្តុតាងទាំងអស់នោះបង្ហាញទណ្ឌិត **ទីម សាខន** បុគ្គលរូបនេះបានឃើញដូច្នេះហើយក៏មានការអៀនខ្មាស និងភ័យខ្លាចនឹងទង្វើរបស់គេ ទើបធ្វើសំណូមពរឱ្យខ្លួនគេវិលត្រឡប់ទៅរស់នៅឯស្រុកកំណើតវិញ (កម្ពុជាក្រោម) ពុំមានអាជ្ញាធរណាម្នាក់ចាប់បង្ខំបញ្ជូនទណ្ឌិតរូបនេះឱ្យអាជ្ញាធរវៀតណាមនោះឡើយ ។

ខ្ញុំព្រះករុណា អាត្មាភាពខ្ញុំ សូមឯកឧត្តម លោកជំទាវ មន្ត្រីរាជការ គ្រប់បណ្តាថ្នាក់ និងគណៈបក្សនយោបាយទាំងអស់ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាល សូមព្រះមេត្តាទទួលយកនូវសេចក្តីបំភ្លឺនេះដោយស្មោះស្ម័គ្របំផុត និងទទួលយកនូវសេចក្តីស្រឡាញ់រាប់អានជាបង ជាប្អូន ជាមហាគ្រួសារក្នុងព្រះពុទ្ធសាសនាដ៏ត្រជាក់របស់យើងទាំងអស់គ្នា ។

ព.ស.២៥៥១
គ.ស.២០០៧

ថ្ងៃ[illegible] រាជធានីភ្នំពេញ, ថ្ងៃទី...១...២...ខែកក្កដា

សម្តេចព្រះមហាសង្ឃរាជ

ទេព_វង្ស

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យព្រះមហាក្សត្រ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងព័ត៌មាន
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងធម្មការ និងសាសនា

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ